កុមាររៀន
កុមារចេះ
ក ១ ២៣

# ធានីជាចៅតាសៅ



# ធានីជាចៅតាសៅ



និពន្ធដោយ ៖ **អ្នកស្រី ហ៊ុយ ឆេងរតនា**
វិចិត្ររូបភាពដោយ ៖ **លោក សួ គឹមសាន**

**កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា**


រឿង៖ **ធានីជាចៅតាសៅ**

និពន្ធ និងរៀបរៀងដោយ៖ **អ្នកស្រី ហ៊ុយ ឆេងរតនា**

វិចិត្ររូបភាពដោយ៖ **លោក សួ គឹមសាន**



សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។



សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។


ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

Let's Read

www.LetsReadAsia.org

ធានីជាចៅតាសៅ។
តាសៅជាជីតាធានី។



តាសៅដាំដំណាំ។
តានីចេះដាំដំណាំដែរ។



តាសៅដាំអំពៅ។
ធានីចេះដាំអំពៅដែរ។



តាសៅកេះតាខេ។
ផានីសួរសំណួរអំពីតាខេ។



ខោធានីធូរ។





តាសៅដេរខោធានី។

ធានីទះដៃអរ។

ទំនេរពីការងារ តាសៅនាំធានីគូរ
គំនូរ។ ធានីចេះគូរគំនូរតាសៅ។



# តាសៅឈឺដៃ។





ធានីអាសូរតាសៅ។
ធានីចេះថែទាំតា។





តាសៅជាពីជំងឺ។

ផានីទះដៃអរ។





តាសៅទៅសាលាឃុំ។

ធានីសុំតាទៅសាលាឃុំដែរ។

តាសៅបររទេះគោនាំធានីទៅ
សាលាឃុំ។ ធានីអរ សំពះតាសៅ។



នៅសាលាឃុំ ផានីចេះសំពះតាៗ។
តាៗសរសើរផានី។



ផានីចាំតានៅសាលាឃុំ។
ផានីគូរគំនូរ។



កុមារដទៃគូរគំនូរដែរ។



តាសៅ បររទេះគោនាំធានី
ទៅលំនៅ។



# ពន្យល់ពាក្យ

១. **តាខេ** : ឈ្មោះគ្រឿងភ្លេងបុរាណមួយប្រភេទ

២. **លំនៅ** : ផ្ទះ

៣. **អាសូរ** : អាណិត

៤. **ថៃទាំ** : រក្សា បីបាច់ ថែដោយប្រុងប្រយ័ត្ន

៥. **សរសើរ** : លើកតម្កើង និយាយលើក



# សំណួរ

១. តើជីតារបស់ធានីឈ្មោះអ្វី?

២. ចូរកូនរៀបរាប់នូវអ្វីដែលធានីរៀនចេះពីជីតារបស់នាង ឱ្យបានពីរ។

៣. តើកូនគិតថា ធានីស្រឡាញ់ជីតារបស់នាងដែរឬទេ? ហេតុអ្វី?

៤. តើកូនមានជីតាដែរឬទេ? តើកូនបានរៀនចេះអ្វីខ្លះពីជីតារបស់កូន?














IPEA, Kg.Chhnang, 789 copies, SSK, Oct. 2022

បន្ទាប់ពីរៀនចប់មេរៀនទី៣ **«រំពូកព្យញ្ជនៈផ្សំស្រៈ»** នៃសៀវភៅថ្នាក់ទី២ សិស្សនឹងអាចអានសៀវភៅរឿងនេះបានដោយខ្លួនឯង ដោយពុំចាំបាច់មានអ្នកដទៃជួយឡើយ។

ទោះជាយ៉ាងណា សិស្សថ្នាក់ទី១ ក៏អាចអានសៀវភៅរឿងនេះជាមួយគ្រូបានដែរ ដោយពួកគេអាចមើលនិងរៀបរាប់អំពីរូបភាពនៅក្នុងសៀវភៅរឿងនេះ ហើយអានពាក្យនិងតួអក្សរដែលពួកគេស្គាល់។

សូមចងចាំថា នៅពេលសិស្សចាប់ផ្តើមអានសៀវភៅកាន់តែឆាប់ គឺកាន់តែប្រសើរសម្រាប់ពួកគេ!



កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

9 789924 560326

បោះពុម្ពឆ្នាំ២០២២